ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

តុលាការកំពូល

សភាព្រហ្មទណ្ឌ
សំណុំរឿងព្រហ្មទណ្ឌ
លេខ: ១៤
ចុះថ្ងៃទី០៨ ខែមករា ឆ្នាំ២០១៨
សាលដីកា
លេខ: ១០ "I"
ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០២០

# សាលដីកា

## តាមនាមប្រជារាស្ត្រខ្មែរ

## តុលាការកំពូល

បានបើកសវនាការជាសាធារណៈ នៅថ្ងៃទី១០ ខែមករា ឆ្នាំ២០២០

ដោយមានសមាសភាពអង្គជំនុំជម្រះដូចខាងក្រោម ៖

១.ឯកឧត្តម [redacted] ប្រធានអង្គជំនុំជម្រះ

២.លោក [redacted] ចៅក្រម

៣.លោក [redacted] ចៅក្រម

៤.លោក [redacted] ចៅក្រម

៥.លោកស្រី [redacted] ចៅក្រមរបាយការណ៍

## ក្រឡាបញ្ជីសវនាការ

លោក [redacted]

## តំណាងមហាអយ្យការ

លោក [redacted] ព្រះរាជអាជ្ញា

## ដើម្បីជំនុំជម្រះ

លើពាក្យបណ្តឹងសាទុក្ខលេខ ៤៤១ ចុះថ្ងៃទី១៣ ខែវិច្ឆិកា ឆ្នាំ២០១៨ របស់ ឯកឧត្តមអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ និងបណ្តឹងសាទុក្ខលេខ ៤៤២ ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០១៨ របស់ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ចន្ថា ចំពោះសាលដីកាព្រហ្មទណ្ឌលេខ ៤៨ ក្រVI "ស" ចុះថ្ងៃទី១៧ ខែតុលា ឆ្នាំ២០១៨ របស់សភាព្រហ្មទណ្ឌនៃសាលាឧទ្ធរណ៍ ដែលមាន ៖

**ជនជាប់ចោទឈ្មោះ** [redacted] ម៉ារ៉ា ភេទស្រី អាយុ៥៧ឆ្នាំ ជនជាតិខ្មែរ មុខរបរអាជីវករ ទីកន្លែងកំណើតសង្កាត់លេខ៣ ក្រុងភ្នំពេញ ទីលំនៅបច្ចុប្បន្ន ផ្ទះលេខ [redacted] រាជធានីភ្នំពេញ ឪពុកឈ្មោះ [redacted] "ស" ម្តាយឈ្មោះ [redacted] "រ" ប្តីឈ្មោះ [redacted] មានកូន០៤នាក់ ទោសពីមុនគ្មាន ។



Scanned with CamScanner

មេធាវីការពារសិទ្ធិ លោក [redacted] ឌា ។

ជាប់ចោទពីបទ ៖ ឆបោក ប្រព្រឹត្តនៅរាជធានីភ្នំពេញ កាលពីអំឡុងខែសីហា ឆ្នាំ២០១២ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោស តាមបញ្ញត្តិមាត្រា ៣៧៧ និងមាត្រា ៣៧៨ នៃក្រមព្រហ្មទណ្ឌ ។

ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ចន្ធា ភេទប្រុស អាយុ៥៦ឆ្នាំ ជនជាតិខ្មែរ ទីលំនៅបច្ចុប្បន្ន ភូមិ [redacted] រាជធានីភ្នំពេញ ។ (អ្នកប្តឹងសាទុក្ខ)

មេធាវីការពារសិទ្ធិ លោក [redacted] មនោរម្យ ។

ឯកឧត្តមអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ អ្នកប្តឹងសាទុក្ខ ។

អំពីអង្គហេតុ ៖

កាលពីថ្ងៃទី០៥ ខែឧសភា ឆ្នាំ២០១១ ជនជាប់ចោទឈ្មោះ [redacted] ហាក់ និងឈ្មោះ [redacted] ម៉ារ៉ា បានទិញដីពីជនរងគ្រោះឈ្មោះ [redacted] ចន្ធា ភេទប្រុស អាយុ៥៦ឆ្នាំ ទំហំ ៧៩៨៥,៣៧ ម៉ែត្រការ៉េ ស្ថិតនៅភូមិមិត្តភាព ផ្លូវលេខ១០ សង្កាត់ព្រែកឯង ខណ្ឌច្បារអំពៅ ក្នុងតម្លៃ ២៥(ម្ភៃប្រាំ)ដុល្លារអាមេរិក សរុបទឹកប្រាក់ចំនួន ១៩៩.៦៣៤(ដប់ប្រាំបួនម៉ឺនប្រាំបួនពាន់ប្រាំមួយរយសាមសិបបួន)ដុល្លារអាមេរិក ។ ជនរងគ្រោះបានទទួលប្រាក់ពីជនជាប់ចោទចំនួន ១៥៤.០០០(ដប់ប្រាំម៉ឺនបួនពាន់)ដុល្លារអាមេរិក ហើយបានផ្ទេរវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុដាក់ឈ្មោះ [redacted] ហាក់ និងឈ្មោះ [redacted] ម៉ារ៉ា រួចហើយ ។ ប្រាក់នៅសល់ចំនួន ៤៥.៦៣៤ (បួនម៉ឺនប្រាំពាន់ប្រាំមួយរយសាមសិបបួន)ដុល្លារអាមេរិក ជនជាប់ចោទបានសន្យាថា និងប្រគល់ឱ្យជនរងគ្រោះក្នុងខែសីហា ឆ្នាំ២០១២ ។ ដល់ពេលកំណត់ជនជាប់ចោទពុំបានប្រគល់ប្រាក់ឱ្យជនរងគ្រោះដូចការសន្យានោះទេ ហើយបានប្រើឧបាយកលទុច្ចរិតដោយអះអាងថា សុំខ្ចីបណ្ណកម្មសិទ្ធិខាងលើយកទៅបញ្ចាំនៅធនាគាររួចមក ជនជាប់ចោទទាំងពីរនាក់ខាងលើពុំបានយកប្រាក់មកប្រគល់ឱ្យជនរងគ្រោះឡើយ ។

-បានឃើញ សាលក្រមព្រហ្មទណ្ឌលេខ ២១២៥ "ញ" ចុះថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១៧ របស់សាលាដំបូងរាជធានីភ្នំពេញ ដែលមានខ្លឹមសារនៃសេចក្តីសម្រេចដូចតទៅ ៖

១-ឱ្យឈ្មោះ [redacted] ហាក់ ភេទប្រុស ដែលមានសាវតាជាតិដូចខាងលើ បានរួចផុតពីបទ ឆបោក ប្រព្រឹត្តនៅរាជធានីភ្នំពេញ កាលពីអំឡុងខែសីហា ឆ្នាំ២០១២ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៣៧៧ និងមាត្រា ៣៧៨ នៃក្រមព្រហ្មទណ្ឌ ។

២-ផ្តន្ទាទោសឈ្មោះ [redacted] ម៉ារ៉ា ភេទស្រី ដែលមានសាវតាជាតិដូចខាងលើ ដាក់ពន្ធនាគារកំណត់ ០១ (មួយ)ឆ្នាំ តែទោសដាក់ពន្ធនាគារនេះឱ្យជនជាប់ចោទអនុវត្តទោសព្យួរតាមមាត្រា ១០៦ និងមាត្រា ១០៧ នៃក្រមព្រហ្មទណ្ឌ ។

ពីបទ ឆបោក ប្រព្រឹត្តនៅរាជធានីភ្នំពេញ កាលពីអំឡុងខែសីហា ឆ្នាំ២០១២ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៣៧៧ និងមាត្រា ៣៧៨ នៃក្រមព្រហ្មទណ្ឌ ។



Scanned with CamScanner

៣-បង្គាប់ឱ្យជនជាប់ចោទឈ្មោះ [redacted] ម៉ាន់ សងសំណងការខូចខាតចំនួន ៤៥.៦៣៤(សែសិបប្រាំពាន់ប្រាំមួយរយសាមសិបបួន)ដុល្លារអាមេរិក និងសងសំណងជម្ងឺចិត្តចំនួន ១០.០០០.០០០(ដប់លាន)រៀល ឱ្យទៅដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ចន្ថា ។ ការទាមទារលើសពីនេះច្រានចោល ។

សាលក្រមនេះ ជំនុំជម្រះជាសាធារណៈនៅថ្ងៃទី០៩ ខែសីហា ឆ្នាំ២០១៧ វេលារសៀល និងប្រកាសជាសាធារណៈនៅថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១៧ វេលារសៀល កំបាំងមុខជនជាប់ចោទឈ្មោះ [redacted] ម៉ាន់ ឈ្មោះ [redacted] ហាន់ និងកំបាំងមុខដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ចន្ថា ។

ទុកសិទ្ធិប្តឹងទាស់ និងប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់ ។

-បានឃើញ បណ្តឹងឧទ្ធរណ៍លេខ ៦៩០ ចុះថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ២០១៧ របស់ជនជាប់ចោទឈ្មោះ [redacted] ម៉ាន់ ដែលប្តឹងមិនសុខចិត្តនឹងសាលក្រមព្រហ្មទណ្ឌលេខ ៦១២៥ "ញ" ចុះថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១៧ របស់សាលាដំបូងរាជធានីភ្នំពេញ ត្រង់ចំណុចនៃសេចក្តីសម្រេចទាំងមូល ។

-បានឃើញ សាលដីកាព្រហ្មទណ្ឌលេខ ៤៨ ក្រVI "ស" ចុះថ្ងៃទី១៧ ខែតុលា ឆ្នាំ២០១៨ របស់សភាព្រហ្មទណ្ឌនៃសាលាឧទ្ធរណ៍ ដែលមានខ្លឹមសារនៃសេចក្តីសម្រេចដូចតទៅ ៖

១-ទទួលបណ្តឹងឧទ្ធរណ៍លេខ ៦៩០ ចុះថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ២០១៧ របស់ឈ្មោះ [redacted] ម៉ាន់ ទុកជាត្រឹមត្រូវតាមច្បាប់ ។

២-បដិសេធសាលក្រមព្រហ្មទណ្ឌលេខ ៦១២៥ "ញ" ចុះថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១៧ របស់សាលាដំបូងរាជធានីភ្នំពេញ ចោល ។

៣-ឱ្យឈ្មោះ [redacted] ម៉ាន់ ភេទស្រី រួចផុតពីបទ ឆបោក ប្រព្រឹត្តនៅរាជធានីភ្នំពេញ កាលពីអំឡុងខែសីហា ឆ្នាំ២០១២ បទល្មើសព្រហ្មទណ្ឌមានចែង និងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៣៧៧ មាត្រា ៣៧៨ នៃក្រមព្រហ្មទណ្ឌ ។

៤-សាលដីកានេះ ជំនុំជម្រះជាសាធារណៈនៅថ្ងៃទី១៨ ខែកញ្ញា ឆ្នាំ២០១៨ ប្រកាសជាសាធារណៈនៅថ្ងៃទី១៧ ខែតុលា ឆ្នាំ២០១៨ ចំពោះមុខឈ្មោះ [redacted] មនោរម្យ ជាមេធាវីការពារផលប្រយោជន៍ដើមបណ្តឹង កំបាំងមុខដើមបណ្តឹង តែចាត់ទុកចំពោះមុខ កំបាំងមុខឈ្មោះ [redacted] ម៉ាន់ ជាជនត្រូវចោទ បើកផ្លូវសាទុក្ខ និងតវ៉ាតាមច្បាប់ ។

-បានឃើញ បណ្តឹងសាទុក្ខលេខ ៤៤១ ចុះថ្ងៃទី១៣ ខែវិច្ឆិកា ឆ្នាំ២០១៨ របស់ ឯកឧត្តមអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ដែលប្តឹងមិនសុខចិត្តនឹងសាលដីកាព្រហ្មទណ្ឌលេខ ៤៨ ក្រVI "ស" ចុះថ្ងៃទី១៧ ខែតុលា ឆ្នាំ២០១៨ របស់សភាព្រហ្មទណ្ឌនៃសាលាឧទ្ធរណ៍ ត្រង់ចំណុចឱ្យឈ្មោះ [redacted] ម៉ាន់ ភេទស្រី រួចផុតពីបទចោទ ឆបោក ។



Scanned with CamScanner

-បានឃើញ បណ្តឹងសាទុក្ខលេខ ៤៤២ ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០១៨ របស់ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted]ចន្ថា ដែលប្តឹងមិនសុខចិត្តនឹងសាលដីកាព្រហ្មទណ្ឌលេខ ៤៨ ក្រVI "ស" ចុះថ្ងៃទី១៧ ខែតុលា ឆ្នាំ២០១៨ របស់សភាព្រហ្មទណ្ឌនៃសាលាឧទ្ធរណ៍ ត្រង់ចំណុចនៃសេចក្តីសម្រេចទាំងមូល ។

**នាពេលសវនាការ**

-ចៅក្រមបានអានរបាយការណ៍ ។

-តំណាងមហាអយ្យការអមតុលាការកំពូល ធ្វើសេចក្តីសន្និដ្ឋានសុំថា ៖

យល់ឃើញដូចជាការប្តឹងសាទុក្ខរបស់អយ្យការអមសាលាឧទ្ធរណ៍ផងដែរ ។ ជនជាប់ចោទ បានប្រើឧបាយកលទុច្ចរិត ដែលជាធាតុផ្សំ ក្នុងអំពើឆបោក ដើម្បីខ្លួនបានទទួលនូវអត្ថប្រយោជន៍ ដែលអំពើនោះ គឺជនជាប់ចោទបានប្រើវិធីកិច្ចសន្យាទិញលក់ តែបែរជាលួងលោម ខ្ចីប្លង់ដី យកទៅដាក់បញ្ចាំ ហើយបានយកប្រាក់ គេចខ្លួនបាត់ ។ ហេតុដូច្នេះ អំពើនេះ គឺជាអំពើឆបោកប្រាកដមែន ។

ហេតុដូច្នេះ

តំណាងមហាអយ្យការ ប្តឹងសុំចំពោះតុលាការកំពូលឱ្យ ៖

១.ទទួលបណ្តឹងសាទុក្ខលេខ ៤៤១ ចុះថ្ងៃទី១៣ ខែវិច្ឆិកា ឆ្នាំ២០១៨ និងបណ្តឹងសាទុក្ខលេខ ៤៤២ ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០១៨ ។

២.បដិសេធចោលទៅលើសាលដីកាព្រហ្មទណ្ឌលេខ ៤៨ ក្រVI "ស" ចុះថ្ងៃទី១៧ ខែតុលា ឆ្នាំ២០១៨ ។

-លោក [redacted]មនោរម្យ ជាមេធាវីការពារសិទ្ធិឱ្យដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted]ចន្ថា បានធ្វើសេចក្តីសន្និដ្ឋានថា ៖ កូនក្តីខ្ញុំបាទប្តឹងសាទុក្ខ គឺសាលាឧទ្ធរណ៍មិនបានផ្តល់ភាពយុត្តិធម៌ជូនគាត់ សាលាឧទ្ធរណ៍មិនបានពិចារណាទៅលើអង្គហេតុ និងធាតុផ្សំ ។ សាលាឧទ្ធរណ៍គាត់យល់ថា ជារឿងរដ្ឋប្បវេណី ជនជាប់ចោទឈ្មោះ [redacted]ម៉ារ៉ា និងប្តីឈ្មោះ [redacted]ម៉ាក់ បានទៅទិញដីមួយកន្លែងពីកូនក្តីខ្ញុំតម្លៃសរុប ១៩៦.០០០(ដប់ប្រាំបួនម៉ឺនប្រាំមួយពាន់)ដុល្លារអាមេរិក ក្នុងខែឧសភា ឆ្នាំ២០១១ ក្រោយមកគាត់បានប្រគល់ប្រាក់ឱ្យកូនក្តីខ្ញុំបាទបាន ១៥៤.០០០(ដប់ប្រាំម៉ឺនបួនពាន់)ដុល្លារអាមេរិក ទឹកប្រាក់ជំពាក់កូនក្តីខ្ញុំ ៤៥.៦៣៤(សែសិបប្រាំពាន់ប្រាំមួយរយសាមសិបបួន)ដុល្លារអាមេរិក ដោយគាត់សន្យាក្នុងខែសីហា ឆ្នាំ២០១២ ប៉ុន្តែនៅពេលដល់ថ្ងៃខែហើយ ទឹកប្រាក់ដែលគាត់ត្រូវផ្តល់ឱ្យកូនក្តីខ្ញុំទៀត ៤៥.៦៣៤(សែសិបប្រាំពាន់ប្រាំមួយរយសាមសិបបួន)ដុល្លារអាមេរិក ប្រាក់បង្គ្រប់នេះ គឺគាត់គ្មានលទ្ធភាពផ្តល់ឱ្យកូនក្តីខ្ញុំទេ ប៉ុន្តែប្លង់កម្មសិទ្ធិកូនក្តីខ្ញុំបានផ្ទេរទៅលោកស្រី [redacted]ម៉ារ៉ា រួចហើយ ដូច្នេះ លោកស្រី [redacted]ម៉ារ៉ា អត់មានលុយឱ្យកូនក្តីខ្ញុំ ក៏លួងលោមនិយាយសុំខ្ចីប្លង់កូនក្តីខ្ញុំយកទៅដាក់ធនាគារសិន នៅពេលបានលុយពីធនាគារស្រាប់តែដាក់មេប្រូច លុយដែលជំពាក់កូនក្តីខ្ញុំនៅដដែល ។



Scanned with CamScanner

រឿងនេះ គ្រប់នីតិវិធីតាំងពីសាលាដំបូងរហូតមកដល់តុលាការកំពូល គឺឈ្មោះ [redacted]ម៉ារ៉ា គេចខ្លួនរហូតមិនព្រមចូលខ្លួន ។

ខ្ញុំបាទជាមេធាវីតំណាងឱ្យដើមបណ្តឹងរដ្ឋប្បវេណី សំណូមពរមេត្តាច្រានចោលសាលដីការបស់សាលាឧទ្ធរណ៍លេខ ៤៨ ក្រVI "ស" ចុះថ្ងៃទី១៧ ខែតុលា ឆ្នាំ២០១៨ របស់សាលាឧទ្ធរណ៍ សុំបង្វិលទៅឧទ្ធរណ៍វិញ ។

-ក្រោយពីបានស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី

-ក្រោយពីបានពិនិត្យ ពិចារណា ពិភាក្សា វិនិច្ឆ័យ ត្រឹមត្រូវតាមច្បាប់ហើយ

**តុលាការកំពូល**

១-យល់ឃើញថា បណ្តឹងសាទុកលេខ ៤៤១ ចុះថ្ងៃទី១៣ ខែវិច្ឆិកា ឆ្នាំ២០១៨ របស់ **ឯកឧត្តមអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍** និងបណ្តឹងសាទុក្ខលេខ ៤៤២ ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០១៨ របស់ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted]ចន្ថា ធ្វើឡើងក្នុងកំណត់ច្បាប់ តុលាការកំពូលអាចលើកយករឿងនេះមកជំនុំជម្រះបានតាមបទប្បញ្ញត្តិមាត្រា ៦៤ នៃ ច្បាប់ស្តីពីការរៀបចំអង្គការតុលាការ និងបទប្បញ្ញត្តិមាត្រា ៤១៧ មាត្រា ៤១៨ និងមាត្រា ៤២០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

២-យល់ឃើញថា សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការអមតុលាការកំពូលនាពេលសវនាការ ក៏ដូចជាសេចក្តីសន្និដ្ឋានជាលាយលក្ខណ៍អក្សរដែរថា បណ្តឹងសាទុក្ខលេខ ៤៤១ ចុះថ្ងៃទី១៣ ខែវិច្ឆិកា ឆ្នាំ២០១៨ របស់ **ឯកឧត្តមអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍** និងបណ្តឹងសាទុក្ខលេខ ៤៤២ ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០១៨ របស់ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted]ចន្ថា ធ្វើឡើងក្នុងកំណត់ច្បាប់ តុលាការកំពូលអាចលើករឿងនេះមកជំនុំជម្រះបាន តាមបទប្បញ្ញត្តិមាត្រា ៦៤ នៃច្បាប់ស្តីពីការរៀបចំអង្គការតុលាការ និងបទប្បញ្ញត្តិមាត្រា ៤២០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ស្របទៅនឹងសំអាងហេតុត្រង់ចំណុចទី១ ខាងលើរបស់អង្គជំនុំជម្រះរបស់តុលាការកំពូល ។

៣-យល់ឃើញថា ឯសេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការអមតុលាការកំពូលនាពេលសវនាការ ក៏ដូចជាសេចក្តីសន្និដ្ឋានជាលាយលក្ខណ៍អក្សរដែរ ពាក់ព័ន្ធនឹងសាលដីការបស់សាលាឧទ្ធរណ៍ថា ខ្លួនក៏យល់ឃើញដូចគ្នាទៅនឹងបណ្តឹងសាទុក្ខ និងសារណាក្នុងបណ្តឹងសាទុក្ខរបស់មហាអយ្យការអមសាលាឧទ្ធរណ៍ដែរ គឺជនជាប់ចោទបានប្រើឧបាយកលទុច្ចរិតដែលជាធាតុផ្សំក្នុងអំពើឆបោក ដើម្បីខ្លួនបានទទួលនូវអត្ថប្រយោជន៍ដែលអំពើនោះគឺជនជាប់ចោទបានប្រើវិធីកិច្ចសន្យាទិញលក់ តែបែរជាលួចលោមខ្ចីប្លង់ដីរបស់ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted]ចន្ថា ថាខ្លួនយកទៅដាក់បញ្ចាំធនាគារយកប្រាក់សងបង្គ្រប់ឱ្យភាគីដើមបណ្តឹងរដ្ឋប្បវេណី



Scanned with CamScanner

(ភាគីលក់) គ្រប់ចំនួន តែក្រោយពីទទួលបានប្លង់ដីហើយ ក៏គេចខ្លួនបាត់ ដូច្នេះ អំពើនេះ គឺជាអំពើឆបោក ប្រាកដមែន ជាសេចក្តីសន្និដ្ឋានមានមូលហេតុអង្គហេតុ បង្ហាញបញ្ជាក់អំពីអំពើប្រព្រឹត្តរបស់ជនជាប់ចោទ និងធាតុផ្សំនៃបទល្មើសដោយផ្អែកតាមអង្គច្បាប់សមស្រប តុលាការកំពូលយល់ស្របនឹងសេចក្តីសន្និដ្ឋាននេះ ។

៤-យល់ឃើញថា សេចក្តីសន្និដ្ឋានរបស់មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីបានលើកឡើងអះអាងថា ការដែលសាលាឧទ្ធរណ៍សម្រេចឱ្យជនជាប់ចោទឈ្មោះ [redacted] ម៉ារ៉ា រួចផុតពីបទឆបោកនេះ ដោយសំអាងហេតុថា អង្គហេតុនៃសំណុំរឿងនេះ គឺជាការមិនគោរពកាតព្វកិច្ចនៃកិច្ចសន្យាទិញលក់ដី ដែលជារឿងរដ្ឋប្បវេណីសុទ្ធសាធនោះ គឺជាការមិនត្រឹមត្រូវទេ ។ ការពិតសាលាឧទ្ធរណ៍យកហេតុផលតែមួយជ្រុងនៃអង្គហេតុទាំងមូលមកពិនិត្យ ពិចារណា សម្រេច ។

អង្គហេតុនៃបទល្មើសឆបោករបស់ជនជាប់ចោទឈ្មោះ [redacted] ម៉ារ៉ា នៅក្នុងសំណុំរឿងនេះត្រង់ថា ជនជាប់ចោទបានប្រើល្បិចកល លួងលោមឱ្យកូនក្តីខ្លួនលក់ដីឱ្យ ហើយសន្យាថា នៅពេលធ្វើបណ្ណកម្មសិទ្ធិប្តូររឹងផ្ទេរដាក់ឈ្មោះខ្លួន(ជនជាប់ចោទ) រួចហើយនោះ គេ(ជនជាប់ចោទ) នឹងប្រគល់ប្រាក់ឱ្យកូនក្តីខ្លួនគ្រប់ចំនួន ។ ប៉ុន្តែនៅពេលកូនក្តីខ្លួនបានផ្ទេរឈ្មោះ និងធ្វើបណ្ណកម្មសិទ្ធិរួចហើយ បែរជាជនជាប់ចោទប្រើឧបាយកលលួងលោម សុំខ្ចីយកប្លង់កម្មសិទ្ធិ (បណ្ណសម្គាល់ម្ចាស់អចលនវត្ថុ) នោះពីកូនក្តីខ្លួនថាយកទៅពិនិត្យសិន បើពិតប្រាកដគេនឹងប្រគល់ប្រាក់ឱ្យគ្រប់ចំនួន ។ ប៉ុន្តែក្រោយពីទទួលបានបណ្ណកម្មសិទ្ធិដីរួច ជនជាប់ចោទបានអះអាងថានឹងយកទៅដាក់បញ្ចាំនៅធនាគារ ដើម្បីយកប្រាក់មកទូទាត់សងឱ្យកូនក្តីខ្លួនគ្រប់ចំនួន ។ ផ្ទុយទៅវិញបន្ទាប់ពីទទួលបានប្រាក់ពីធនាគាររួច ជនជាប់ចោទនៅតែមិនព្រមប្រគល់ប្រាក់មកឱ្យកូនក្តីខ្លួនដដែល ហើយជនជាប់ចោទតែងតែព្យាយាមប្រើល្បិចអូសបន្លាយពេលវេលា និងគេចវេសរហូតមកនោះ គឺជាសេចក្តីសន្និដ្ឋានមានមូលដ្ឋានអង្គហេតុ ភស្តុតាង អង្គច្បាប់សមស្រប ប្រហាក់ប្រហែលគ្នានឹងសេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការអមតុលាការកំពូលដែរ ដែលតុលាការកំពូលអាចយកធ្វើជាមូលដ្ឋានក្នុងការពិនិត្យ ពិចារណា វិនិច្ឆ័យសម្រេចសេចក្តីបាន ។

៥-យល់ឃើញថា ថ្វីត្បិតតែអង្គហេតុនៅក្នុងសំណុំរឿងនេះ កាលពីដើមដំបូងឡើយវាកើតចេញពីកិច្ចសន្យាទិញលក់អចលនវត្ថុពិតមែន ក៏ប៉ុន្តែនៅដំណាក់កាលត្រូវទូទាត់ប្រាក់ថ្លៃលក់ទិញដីចុងក្រោយ បន្ទាប់ពីភាគីបានលក់បានរត់ការផ្ទេរឈ្មោះក្នុងបណ្ណសម្គាល់ម្ចាស់អចលនវត្ថុរួចហើយ ជនជាប់ចោទឈ្មោះ [redacted] ម៉ារ៉ា បានកើតមាននូវចេតនាទុច្ចរិត ដោយបានប្រើឧបាយកលឱ្យដើមបណ្តឹងរដ្ឋប្បវេណីប្រគល់នូវបណ្ណសម្គាល់ម្ចាស់អចលនវត្ថុ ដែលបានផ្ទេរដាក់ឈ្មោះគាត់ ([redacted] ម៉ារ៉ា) ហើយនោះ តាមវិធីលួងលោមដើមបណ្តឹងរដ្ឋប្បវេណីឱ្យប្រគល់បណ្ណសម្គាល់ម្ចាស់អចលនវត្ថុមកឱ្យខ្លួន និងអះអាងថា ដើម្បីយកទៅដាក់បញ្ចាំនៅធនាគារយកប្រាក់មកសងឱ្យដើមបណ្តឹងរដ្ឋប្បវេណីបង្គ្រប់ចំនួនថ្លៃលក់ទិញដី ។ ក៏ប៉ុន្តែតែនៅក្រោយពេលដែលឈ្មោះ [redacted] ម៉ារ៉ា បាន



Scanned with CamScanner

បណ្ណសម្គាល់ម្ចាស់អចលនវត្ថុហើយ ប៉ុន្តែជាមិនបានយកប្រាក់មកទូទាត់ឱ្យដើមបណ្តឹងរដ្ឋប្បវេណីនោះទេ ហើយក៏បាត់ដំណឹង និងគេចវេសរហូតមិនព្រមយកប្រាក់មកទូទាត់សងឱ្យដើមបណ្តឹងរដ្ឋប្បវេណីសោះ ។ អំពើដែលជនជាប់ចោទបានប្រព្រឹត្តដោយប្រើល្បិចកលទុច្ចរិត ដើម្បីទទួលបានបណ្ណសម្គាល់ម្ចាស់អចលនវត្ថុពីដើមបណ្តឹងរដ្ឋប្បវេណីដែលជាភាគីលក់ ហើយបានធ្វើឱ្យខូចប្រយោជន៍ដល់ដើមបណ្តឹងរដ្ឋប្បវេណីដោយអំពើប្រើល្បិចកលទុច្ចរិតនេះហើយ គឺផ្សំធាតុបានជាបទល្មើសឆបោក ដូចមានចែង និងឱ្យផ្តន្ទាទោសតាមបទប្បញ្ញត្តិមាត្រា ៣៧៧ និងមាត្រា ៣៧៨ នៃក្រមព្រហ្មទណ្ឌ ។

៦-យល់ឃើញថា សាលដីកាព្រហ្មទណ្ឌលេខ ៤៨ ក្រVI "ស" ចុះថ្ងៃទី១៧ ខែតុលា ឆ្នាំ២០១៨ របស់សាលាឧទ្ធរណ៍ភ្នំពេញ ដែលបានសម្រេចសេចក្តីមកនេះ មិនត្រឹមត្រូវតាមច្បាប់ទេ ។

## ហេតុដូច្នេះ

## សម្រេចសេចក្តី

១-ទទួលបណ្តឹងសាទុក្ខលេខ ៤៤១ ចុះថ្ងៃទី១៣ ខែវិច្ឆិកា ឆ្នាំ២០១៨ របស់ **អគ្គព្រះរាជអាជ្ញា**របស់សាលាឧទ្ធរណ៍ និងបណ្តឹងសាទុក្ខលេខ ៤៤២ ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០១៨ របស់ភាគីដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ចន្ថា ទុកជាត្រឹមត្រូវតាមទម្រង់ និងគតិច្បាប់ ។

២-បដិសេធសាលដីកាព្រហ្មទណ្ឌលេខ ៤៨ ក្រVI "ស" ចុះថ្ងៃទី១៧ ខែតុលា ឆ្នាំ២០១៨ របស់សាលាឧទ្ធរណ៍ភ្នំពេញ ។

៣-បង្វិលសំណុំរឿងព្រហ្មទណ្ឌលេខ ១៤ ចុះថ្ងៃទី០៨ ខែមករា ឆ្នាំ២០១៨ របស់តុលាការកំពូល ទៅសាលាឧទ្ធរណ៍ភ្នំពេញ ដើម្បីធ្វើការជំនុំជម្រះជាថ្មីឡើងវិញ ។

សាលដីកានេះ ជំនុំជម្រះជាសាធារណៈ នៅថ្ងៃសុក្រ ទី១០ ខែមករា ឆ្នាំ២០២០ និងប្រកាសនាសវនាការជាសាធារណៈ នៅថ្ងៃសុក្រ ទី១៧ ខែមករា ឆ្នាំ២០២០ ។

Scanned with CamScanner